**AIA (Cambodia) Life Insurance Plc**
30th 31st Floor, GIA Tower, Sopheak Mongkul street, Diamond Island, Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

## AIA Cambodia **បញ្ចប់យុទ្ធនាការ Fit for Hope ឆ្នាំ ២០២២ ដោយមានការសហការ និងគាំទ្រដោយក្រសួងកិច្ចការនារី និងការរួមចំណែកពីដៃគូសហការ និងសាធារណជន**

ភ្នំពេញថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០២២ – ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA Cambodia បានបញ្ចប់យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ប្រចាំឆ្នាំ Fit for Hope ដោយជោគជ័យដ៏ធំគួរឲ្យកត់សម្គាល់ក្នុងឆ្នាំនេះ ជាមួយការសហការ និងគាំទ្រពីក្រសួងកិច្ចការនារី រួមនឹងមានការចូលរួមដ៏ច្រើនកុះករពីសាធារណជន និងដៃគូអាជីវកម្មរបស់ក្រុមហ៊ុន។

វេទិកាចុះដល់មូលដ្ឋាន និងសកម្មភាពដទៃរបស់យុទ្ធនាការ Fit for Hope ក៏បានបន្តឡើងវិញបន្ទាប់ពីអាកខានអស់រយៈពេលពីរឆ្នាំ ដែលបណ្ដាលមកពីជំងឺរាតត្បាតកូវីដ-១៩។ ជាលទ្ធផលសរុបរបស់យុទ្ធនាការ Fit for Hope ឆ្នាំនេះបានផ្ដល់ការពិនិត្យ ស្វែងរកជំងឺមហារីកសុដន់ដំណាក់កាលដំបូងដោយឥតគិតថ្លៃរហូតដល់ទៅ ៣.១២៥នាក់ នៅតាមបណ្ដាខេត្តចំនួន ៤ គឺខេត្តកំពត កំពង់ចាម សៀមរាប និងបាត់ដំបង និង ៣ទីតាំងផ្សេងទៀតក្នុងរាជធានីភ្នំពេញ ដែលក្នុងចំណោមនោះបានរកឃើញករណីសង្ស័យចំនួន ៤១៩ ករណី។ យុទ្ធនាការនេះក៏បានរៃអង្គាសទឹកប្រាក់សរុប ៤៥.០០០ដុល្លារអាមេរិក តាមរយៈការបរិច្ចាគពីសាធារណជន និងដៃគូអាជីវកម្ម ដែលទឹកប្រាក់ទាំងអស់នេះបានប្រគល់ជូនមន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្ដីសង្ឃឹម។

ទឹកប្រាក់បរិច្ចាគសរុបដែលផ្ដល់ដល់មន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្ដីសង្ឃឹម បានមកពីការចូលរួមបរិច្ចាគធំពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងធនាគារព្រីនស៍ រួមនឹងការបរិច្ចាគផ្សេងទៀតពី ក្រុមហ៊ុន SP Building Management ឬ អគារ GIA មូលនិធិ KHM Foundations និង ក្រុមហ៊ុន MSA Marketing Solutions Asia ។

ដោយឡែក ដំណើរពណ៌ផ្កាឈូក “Pink Walk” ដ៏ធំរបស់យុទ្ធនាការ Fit For Hope ត្រូវបានចូលរួមពីសំណាក់សាធារណជនរាប់ពាន់នាក់ ដែលបានអញ្ជើញមកចូលរួមដើរនៅទីក្រុងកោះពេជ្រ ជាមួយឈុតសម្លៀកបំពាក់ពណ៌ផ្កាឈូក ដើម្បីប្រារព្ធទិវានៃការយល់ដឹងអំពីជំងឺមហារីកសុដន់។ ព្រឹត្តិការណ៍នាថ្ងៃនោះក៏មានការប្រគំតន្ត្រីដ៏ធំសម្បើមសម្រាប់សាធារណជនចូលដោយសេរី ដើម្បីទស្សនាការសម្ដែងរបស់តារាចម្រៀងល្បីៗប្រចាំកម្ពុជា ក៏ដូចជាការអបអរ និងថ្លែងអំណរគុណដល់សាធារណជន។

ក្នុងកម្មវិធីបិទយុទ្ធនាការនេះក៏ទទួលបានការចូលរួមជាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ ពេជ ពិទូរ្យរដ្ឋា អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី លោក Tan Hak Leh អគ្គនាយកប្រតិបត្តិប្រចាំតំបន់នៃ AIA Group លោក Andrew Loh អគ្គនាយកប្រតិបត្តិ AIA Cambodia លោក យ៉ាន សាឌីន ជានាយកប្រតិបត្តិនៃមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្ដីសង្ឃឹម លោក ដុស ឌីន អគ្គនាយកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងលោក Leslie Lee Chee Wei ជានាយកប្រតិបត្តិគ្រប់គ្រងអាជីវកម្មនៃធនាគារ ព្រីនស៍ បុគ្គលិក និងទីប្រឹក្សាផែនការជីវិតរបស់ AIA Cambodia រួមទាំងដៃគូអាជីវកម្មជាច្រើនទៀត។

លោកជំទាវ ពេជ ពិទូរ្យរដ្ឋា បានមានប្រសាសន៍ថា៖ «មានតែការបង្កើនការយល់ដឹងប៉ុណ្ណោះដែលអាចជួយកាត់បន្ថយអត្រាកើនឡើងនៃជំងឺមហារីកសុដន់ ហើយក្រសួងកិច្ចការនារី នឹងនៅតែបន្តគាំទ្រ AIA Cambodia និងយុទ្ធនាការ Fit For Hope ដើម្បីសម្រេចគោលបំណងមួយនេះ។ យើងក៏លើកទឹកចិត្តក្រុមហ៊ុនក្នុងវិស័យឯកជន

**AIA (Cambodia) Life Insurance Plc**
30th 31st Floor, GIA Tower, Sopheak Mongkul street, Diamond Island, Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

ឲ្យចូលរួមបង្កើតគំនិតផ្តួចផ្តើមផ្សេងៗទៀតទាក់ទងនឹងសុខភាព និងសុមាលភាពរបស់ប្រជាជនកម្ពុជា ដើម្បីបង្កើនគុណភាពជីវិតរស់នៅរបស់ពួកគាត់ឲ្យកាន់តែប្រសើរ»។

លោក យ៉ាន សាឌីន បានមានប្រសាសន៍ថា៖ «យើងសូមអរគុណយ៉ាងជ្រៀលជ្រៅដល់ម្ចាស់ឧបត្ថម្ភក្នុងយុទ្ធនាការ Fit For Hope ទាំងអស់គ្នា ដែលការចូលរួមនេះនឹងជួយបង្កើនការពិនិត្យជំងឺ ការប្រឹក្សា និងការព្យាបាលក្នុងមន្ទីរពេទ្យមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម។ តាមរយៈការបរិច្ចាគ និងការបង្កើនការយល់ដឹងជាសាធារណៈ អំពីហានិភ័យនៃជំងឺមហារីកសុដន់ អាចជួយសង្គ្រោះជីវិតអ្នកជំងឺមហារីកសុដន់ បង្កើនអត្រាជោគជ័យនៃការព្យាបាល និងលើកទឹកចិត្តស្ត្រីនៅកម្ពុជាផ្សេងទៀតឲ្យមានវិធានការទប់ស្កាត់ជំងឺនេះតាំងពីដំណាក់កាលដំបូង»។

លោក Andrew Loh មានបានប្រសាសន៍ថា៖ “ទោះបីជា AIA Cambodia គឺជាអ្នកដឹកនាំយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ដ៏ធំជាងគេនៅកម្ពុជា ភាពជោគជ័យដ៏ធំរបស់ Fit for Hope គឺបានមកពីការសហការ និងគាំទ្រដោយក្រសួងកិច្ចការនារី មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម សាធារណជន អ្នកចូលរួមបរិច្ចាគ និងដៃគូអាជីវកម្មរបស់យើង។ យើងពិតជាអរគុណសម្រាប់ការគាំទ្រ និងចូលរួមរបស់សាធារណជន ដែលនេះជាកម្លាំងចិត្តឲ្យយើងខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការធានាបានថាស្ត្រីនៅកម្ពុជាទាំងអស់ទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ រួមទាំងបង្កើនការយល់ដឹងឲ្យកាន់តែទូលំទូលាយ ដើម្បីឲ្យពួកគាត់អាចប្រយុទ្ធប្រឆាំងនឹងជំងឺមហារីកសុដន់»។

Fit for Hope គឺជាផ្នែកមួយនៃយុទ្ធនាការប្រចាំឆ្នាំរបស់ AIA Cambodia ក្នុងការជួយប្រជាជនកម្ពុជាឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ យុទ្ធនាការនេះក៏ស្របទៅនឹងគំនិតផ្តួចផ្តើម AIA One Billion របស់ AIA Group ដើម្បីជួយមនុស្សមួយពាន់លាននាក់ (១.០០០.០០០.០០០នាក់) នៅអាស៊ីឲ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ នៅឆ្នាំ ២០៣០។

សម្រាប់ព័ត៌មានបន្ថែមអំពី Fit for Hope និងគម្រោងការពារជំងឺធ្ងន់ធ្ងររបស់ AIA Cambodia ក្នុងការការពារគ្រួសារ និងលោកអ្នក សូមទាក់ទងមកកាន់សេវាបម្រើអតិថិជន AIA Client Care តាមរយៈលេខ ០៨៦ ៩៩៩ ២៤២ ឬចូលទៅកាន់គេហទំព័រ aia.com.kh។

## អំពី AIA Cambodia

ក្រុមហ៊ុនធានារ៉ាប់រង AIA Cambodia គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។

ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ AIA Cambodia ធ្វើឡើងស្របតាមគោលបំណងក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ ២០១៧ យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដំបូងបង្អស់នៅកម្ពុជា ផ្តល់ការការពាររហូតដល់ ២៦ ស្ថានភាពជំងឺធ្ងន់ធ្ងរ។

ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា AIA Cambodia ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើង

**AIA (Cambodia) Life Insurance Plc**
30th 31st Floor, GIA Tower, Sopheak Mongkul street, Diamond Island, Phnom Penh,
Kingdom of Cambodia
AIA.COM.KH

# Media Release

ស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។

AIA Cambodia ផ្តោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការ ជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។

យើងខ្ញុំក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។

ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លឹបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លឹបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។

AIA Cambodia គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់

**“ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)”** ពី HR Asia ក្នុង

រយៈពេលពីរឆ្នាំជាប់គ្នា ២០២០ និង ២០២១។

AIA Cambodia មានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។

ព័ត៌មានបន្ថែមតាមរយៈគេហទំព័រ www.aia.com.kh។

**ទំនាក់ទំនងសារព័ត៌មាន**
**ម៉េង ដាណែត**
ប្រធានផ្នែកទំនាក់ទំនងសាធារណៈ
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
Daneth-d.Meng@aia.com